ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

លេខ ១៣៤០ ព.ណ.........

ភ្នំពេញ, ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១១

<u>ជម្រាបជូន</u>

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាប្រធានភ្នាក់ងារអនុវត្តទាំង១៦**

**នៃគម្រោងកម្មវិធីគាំទ្រការអភិវឌ្ឍន៍ពាណិជ្ជកម្ម**

**<u>កម្មវត្ថុ</u>** : សំណើសុំចាត់បញ្ជូនមន្ត្រីចំនួន**ពីររូប** ចូលរួមនៅក្នុងកិច្ចប្រជុំប្រចាំខែ ឧសភា ២០១១

**<u>យោង</u>** : លិខិតលេខ: ១១៥ សហអ របស់ DICO ចុះថ្ងៃទី ២១ មេសា ២០១១

**<u>ភ្ជាប់ជូន</u>** : របៀបវារៈនៃកិច្ចប្រជុំ

តបតាមកម្មវត្ថុខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូន **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជាតំណាងភ្នាក់ងារអនុវត្តគម្រោងកម្មវិធីគាំទ្រការអភិវឌ្ឍន៍ពាណិជ្ជកម្ម (TDSP) មេត្តាជ្រាបថា: ដើម្បីជំរុញការអនុវត្តន៍គម្រោងឲ្យមានប្រសិទ្ធភាព និងមានភាពរលូន នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ (DICO) រៀបចំកិច្ចប្រជុំប្រចាំខែ ឧសភា រវាង DICO និង ភ្នាក់ងារអនុវត្តគម្រោង IAs (Implementing Agencies) ទាំងអស់ ក្នុងគោលបំណងស្វែងយល់អំពីការប្រឈម, ការងាយស្រួល, និងលទ្ធផលនានា ដែលកើតមានឡើងនៅក្នុងការអនុវត្តន៍គម្រោង ។

ដើម្បីធានានូវការអនុវត្តគម្រោងមានប្រសិទ្ធិភាពខ្ពស់ប្រកបដោយតម្លាភាព និងបានទាន់ពេលវេលា ខ្ញុំសូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជាប្រធានភ្នាក់ងារអនុវត្តគម្រោង មេត្តាចាត់បញ្ជូនមន្ត្រីជាថ្នាក់ដឹកនាំ និង មន្ត្រីបង្គោល មកចូលរួមក្នុងកិច្ចប្រជុំខាងលើ ដែលនឹងប្រព្រឹត្តិទៅនៅ<u>ថ្ងៃទី ១៩ ឧសភា ឆ្នាំ ២០១១ វេលាម៉ោង០៨:០០ ព្រឹក</u> នៅសាលប្រជុំនៃក្រសួងពាណិជ្ជកម្ម ។

សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ែន សុវិចារ** (stamp)

**ចាម_ប្រសិទ្ធ**

<u>ចម្លងជូន:</u>
- ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
- ឯកឧត្តម ប៉ាន សូរស័ក្តិ រដ្ឋលេខាធិការ
- ឯកឧត្តម ឌិត ទីណា អនុរដ្ឋលេខាធិការ
- ឯកឧត្តម សុខ សុភ័ក្ត្រ អគ្គនាយកពាណិជ្ជកម្ម
- ឯកសារ កាលប្បវត្តិ